**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២៩/០៤/២០១១ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១១

**ជម្រាបមក**

**លោក ហ៊ឹង យឿន**

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៦៩ AE3 ផ្លូវលេខ ១៧៨ ភូមិ៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ជាតំណាងលោកស្រី **មាស ចន្ធាទី** សមាជិកាក្រុមប្រឹក្សាសង្កាត់ដើមមៀន

**កម្មវត្ថុ**: រឿងទាក់ទងនឹងពាក្យបណ្តឹងបដិសេធសេចក្តីសម្រេចតាមលិខិតលេខ ៥០៣/១១ គ.ជ.ប ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយទាមទារឱ្យផ្តន្ទាទោសលោក **ហ៊ឹង សឿន** តាមជំពូក១១នៃច្បាប់បោះឆ្នោតតំណាងរាស្ត្រ

**យោង** : ពាក្យបណ្តឹងរបស់លោក លេខ ១២៧/១១ គសរ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្នុងកិច្ចប្រជុំនាថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើពាក្យបណ្តឹងរបស់លោក រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា តាមមាត្រា ២៦ និង មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**